ការសំភាសន៏របស់លោកពូ នុត មល់

ក៖ អ្នកធ្វើការសំភាសន៏ឈ្មោះ គង់ អេលី ខ៖ អ្នកដែលត្រូវគេសំភាសន៏ឈ្មោះ នុត មល់

ក៖ ចឹងថ្ងៃនេះជាថ្ងៃទី២១ ខែ១ ឆ្នាំ២០១៧ ខ្ញុំឈ្មោះគង់ អេលី កំពុងតែស្ថិតនៅភូមិក្តីតាកុយ
សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ចឹង ខ្ញុំសូមជំរាបសួរទៅដល់លោកអ៊ុំ
ខ្ញុំធ្វើការឲ្យសាកលវិទ្យាល័យមួយ ដែលនៅសហរដ្ឋអាមេរិច គេកំពុងតែធ្វើនូវគំរោងមួយនឹង។
ដើម្បីជួយទៅដល់លោកពូ អ្នកមីងទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា
ដើម្បីជួយទៅដល់ពួកគាត់ ដើម្បីឲ្យពួកគាត់កត់ត្រាអំពីជីវប្រវត្តិរបស់ពួកគាត់។
ដើម្បីបន្សល់ឲ្យកូនចៅជំនាន់ក្រោយ ឲ្យពួកគាត់បានដឹងបានស្គាល់
អំពីជីវិតកសូរបស់ពួកគាត់។ ចឹង អត់ទោសតើខ្ញុំអាចសួរ អាចធ្វើនូវការសំភាសន៏
ឬក៏សួរសំនួរខ្លះៗទៅដល់លោកពូបានទេ?
ខ៖ បាទ! សួរបាន។
ក៖ ចឹង នូវពេលលោកពូនិយាយ ពួកខ្ញុំនិងកត់ត្រាអំពីអ្វីដែលលោកពូនិយាយ
ដើម្បីឲ្យកូនចៅជំនាន់ក្រោយ របស់លោកពូបានចងចាំអំពី
ការតស៊ូជីវិតរបស់លោកពូបែបម៉េច។ តើឈ្មោះពេញរបស់លោកពូ មានឈ្មោះអ្វីដែរ?
ហើយលោកពូមានឈ្មោះហៅក្រៅដែរអត់? ហើយឈ្មោះមកពីកុមារភាព លោកពូត្រូវបានគេ
ហៅយ៉ាងម៉េចដែរ?
ខ៖ ខ្ញុំបាទ អត់មានឈ្មោះពីរទេ។ ខ្ញុំបាទ មានឈ្មោះតែមួយគត់ គឺឈ្មោះ នុត មល់។
ក៖ ចឹង តើលោកពូនៅចាំថ្ងៃខែឆ្នាំកំនើតរបស់លោកពូ ថាកើតនៅថ្ងៃខែឆ្នាំណាដែរ?
ខ៖ ខ្ញុំបាទ! ចាំ ខ្ញុំកើតនៅថ្ងៃទី៧ ខែ៨ ឆ្នាំ១៩៥៤។
ក៖ តើលោកពូ អាចចាំនៅទីកន្លែងកំនើត លោកពូកើតនៅឯណាដែរ?
ខ៖ ខ្ញុំបាទ! កើតនៅភូមិក្តីតាកុយ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
ក៖ ចឹង សូមអត់ទោសលោកពូ តើលោកពូអាចចាំនៅទីកន្លែងកំនើត
ឬទៅថ្ងៃខែឆ្នាំកំនើតរបស់ឪពុកម្តាយលោកពូ បានដែរទេ?
ខ៖ ខ្ញុំបាទ! មិនបានចាំថ្ងៃខែឆ្នាំកំនើតរបស់ពួកគាត់ទេ
ខ្ញុំចាំតែភូមិកំនើតដែលគាត់បានកើត។
ក៖ ចឹង តើពួកគាត់កើតនៅឯណាដែរទៅលោកពូ?
ខ៖ ពួកគាត់កើតនៅ ភូមិក្តីតាកុយ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

ក៖ ចឹងលោកពូសូមអត់ទោស ខ្ញុំចង់ដឹងអំពីជីវប្រវត្តិ របស់ជីដូនជីតារបស់លោកពូ
តើលោកពូនៅចងចាំអ្វីខ្លះអំពី ការតស៊ូឬជីវប្រវត្តិរបស់ជីដូនជីតារបស់លោកពូ?
ខ៖ ខ្ញុំមិនសូវចាំច្បាស់ទេ គ្រាន់តែលឺពីឪពុកម្តាយពួកគាត់និយាយតៗគ្នា
ថាពួកគាត់ជាអ្នកជំនួញមួយ ជំនាន់នោះគេប្រើទៅរកស៊ីនៅស្រុកយួនណាស់។
ទៅទិញពោតក្រហមអីចឹងទៅ ខ្ញុំចាំបានតែប៉ុណ្ណឹង។
ក៖ ចឹង លោកពូនៅចាំអំពីថ្ងៃខែឆ្នាំកំនើតរបស់ពួកគាត់ ឬទីកន្លែងកំនើតដែលគាត់បានកើត
ដែរឬអត់លោកពូ?
ខ៖ តាយាយរបស់ខ្ញុំ?
ក៖ ចាស!
ខ៖ យាយរបស់ខ្ញុំគាត់ កើតនៅ ភូមិក្តីតាកុយ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
ដល់ជីតារបស់ខ្ញុំ គាត់កើតនៅខេត្តកំពង់ចាម។
ក៖ ចឹង តើលោកពូនៅចាំ ថាតើពេលបច្ចុប្បន្ននឹង ជីដូនជីតារបស់លោកពូ
ពួកគាត់មានអាយុប៉ុន្មានដែរ?
ខ៖ ពួកគាត់ស្លាប់តាំងពីខ្ញុំមិនទាន់កើតម្ល៉េះនោះ។
ក៖ ចឹង តើលោកពូនៅចាំអំពីអាយុ របស់ឪពុកម្តាយរបស់លោកពូ ថាតើចាប់ពីពេលឥលូវនឹង
ពួកគាត់មានអាយុប៉ុន្មានដែរ?
ខ៖ កាលគាត់ស្លាប់នៅក្នុងអាយុ៥៦ឆ្នាំ មកដល់បច្ចុប្បន្ននេះមិនដឹងជាបួកទៅប៉ុន្មានទៀតទេ
លុះត្រាតែយើងបួកសារជាថ្មីទៀតបានដឹង។

កៈ ចុះ អាយុរបស់លោកពូវិញ នៅក្នុងពេលបច្ចុប្បន្នលោកពូ មានអាយុប៉ុន្មានដែរ?
ខៈ សព្វថ្ងៃនេះ ខ្ញុំមានអាយុ៦៣ឆ្នាំតាមកំនត់ដែលបញ្ជីជាតិរបស់ខ្ញុំ។
កៈ តើលោកពូមានក្រុមគ្រួសារ ឬបងប្អូនសាច់ញាតិអ្វីផ្សេងទៀត
ដែលពួកគាត់ផ្លាប់បានទៅរស់នៅ ក្រៅប្រទេសដែរទេ?
ខៈ គឺថាបងប្អូនរបស់ខ្ញុំ អត់មានអ្នកណាបានទៅរស់នៅក្រៅប្រទេសទេ។
កៈ ខ្ញុំសូមការអនុញ្ញាតពីលោកពូ ដើម្បីសួរអំពីការរៀបការរបស់លោកពូ
អាពាហ៍ពិពាហ៍របស់លោកពូ។ ចឹង តើលោកពូនៅចាំថ្ងៃខែឆ្នាំកំនើត
អាពាហ៍ពិពាហ៍របស់លោកពូ ដែរឬអត់?
ខៈ ខ្ញុំចាំតែឆ្នាំ ថ្ងៃខែអត់ចាំទេ។
កៈ ចឹង នៅឆ្នាំណាដែរលោកពូ?
ខៈ ខ្ញុំការនៅឆ្នាំ១៩៧៣។
កៈ ចាស! តើការរៀបអាពាហ៍ពិពាហ៍របស់លោកពូ បានប្រព្រឹត្តិទៅយ៉ាងដូចម្តេចដែរ?
ខៈ ខ្ញុំនៅចំជំនាន់ សង្គមលុននល់ ការបានតែមួយព្រឹកទេដូចសព្វថ្ងៃនឹង។
កៈ ចឹង តើលោកពូនៅចាំអំពីការជួបគ្នា ជាលើកដំបូងរបស់លោកពូ និងអ្នកមីងដែរឬទេ?
ខៈ កាលនោះពួកខ្ញុំអត់បានជួបទាក់ទងគ្នាទេ គឺបងខ្ញុំជាអ្នកចូលស្តីដណ្តឹងឲ្យ។
កៈ ចឹងខ្ញុំចង់ដឹងអំពីការរៀបការរបស់លោកពូ តើការនោះជំនាន់នោះ
របៀបថាលោកពូមានការស្តីដណ្តឹង ឬធ្វើយ៉ាងម៉េចដែរ ទើបបានអ្នកមីងមកធ្វើជាភរិយា?
ខៈ កាលនោះគឺបងរបស់ខ្ញុំជាអ្នកចូលស្តីដណ្តឹង ឪពុកម្តាយខាងស្រីនឹង
គេព្រមព្រៀនឲ្យខ្ញុំចូលស្តីដណ្តឹងតាមប្រពៃណី។
កៈ ចឹង សូមអត់ទោសលោកពូ តើលោកពូនៅចងចាំ អំពីជីវប្រវត្តិរបស់លោកពូ
នៃការតស៊ូរបស់លោកពូ ពីកុមារភាពរហូតមកដល់ពេលបច្ចុប្បន្ននឹង?
លោកពូមានជីវិតតស៊ូយ៉ាងដូចម្តេចខ្លះ តើលោកពូអាចប្រាប់ដល់ខ្ញុំបានដែរទេ?
ខៈ ខ្ញុំនិយាយបានតិចតួចបើសិនជាខ្ញុំនៅចាំ
ម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីខ្ញុំមានអាយុ៤ឆ្នាំ។ ក្រោយពីនោះមក
ឪពុកខ្ញុំជាអ្នកចិញ្ចឹមរហូតមក ខ្ញុំមានបងប្អូន៥នាក់ ខ្ញុំគឺជាកូនពៅគេ។ ឪពុកខ្ញុំពីដើមឡើយ
គាត់ធ្វើការសហករដ្ឋទុន យើងនៅចំការមននឹង។ ដល់ពេលខ្ញុំក៏បានរៀនត្រឹមថ្នាក់ទី៧
ថ្នាក់ទី៧ជូនឪពុកខ្ញុំក៏បានស្លាប់ចោលខ្ញុំទៅទៀត គាត់ឈឺស្លាប់ខ្ញុំក៏ធ្លាប់ខ្លួនធ្វើជាជាងសំណង់។
ហើយដល់ឪពុកខ្ញុំស្លាប់ទៅទៀតទៅ ខ្ញុំបានបងបង្កើតយកមកចិញ្ចឹម
ដូចជាគ្រួសារនឹងខ្ញុំក៏បំរើគាត់ដូចជា ពីដើមគេថា ទៅរាយម៉ុងតាមសន្តូចចឹងទៅណា។
កៈ ចឹងលោកពូ នៅចាំថាតើលោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?
ខៈ ខ្ញុំមានបងប្អូរជ្រាំនាក់ ទាំងរូបខ្ញុំ។
កៈ ចឹង តើលោកពូអាចជួយប្រាប់ខ្ញុំបន្តិច ថាតើបងប្អូនលោកពូ
ពួកគាត់មានស្ថានភាពដូចម្តេចដែរ?
ខៈ ស្ថានភាពបងប្អូងរបស់ខ្ញុំពួកគាត់ជាអ្នក បងទីមួយ
គាត់គឺជាអ្នកនេសាទទិញបឹងទិញអីចឹងទៅណា ដើម្បីយកលុយមកចិញ្ចឹមជីវិតព្រមទាំងខ្ញុំដែល។
ហើយបងទីពីរនោះគាត់ធ្វើជាទាហាន នៅជំនាន់លុននល់
បងទីបីនោះក៏ធ្វើជាទាហានលុននល់ដែល បានប្តីជាអ្នកធ្វើទាហានលុននល់ទាំងអស់។
ហើយចំណែកខ្ញុំ និងបងខ្ញុំក៏បានត្រូវគេចាប់ឲ្យធ្វើជាទាហាន
នៅជំនាន់លុននល់ដែលនៅឆ្នាំ១៩៧៣ដែល។
កៈ ចឹង តើលោកពូមានភាពលំបាកអ្វីខ្លះ នៅក្នុងជីវិតរបស់លោកពូ? ដែលលោកពូចងចាំថា
វាជាការលំបាកបំផុតនៅក្នុងជីវិតរបស់លោកពូ?
ខៈ ពិបាកនៅក្នុងចិត្តរបស់ខ្ញុំនៅក្នុងជំនាន់នោះគឺ ពិបាកម៉េចគឺពិបាកថា
មកពីរៀនទៅជ្រុតក្តាមដើម្បីយកលុយទៅធ្វើសន្តូច។ ហើយមួយទៀតដើរលេងអត់បានទេ
គឺត្រូវមើលគោផង ដើររាយសន្តូចផង អត់មានពេលសំរាក អត់មានពេលរៀនសូត្រ
ខ្ញុំក៏ដាច់ចិត្តឈប់ពីជំនាន់នោះទៅ។
កៈ ចឹងលោកពូ កាលនៅជំនាន់នោះ តើលោកពូមានបានទៅរៀនអ្វី ដែរទេ?

ខ៖ ជំនាន់នោះដូចខ្ញុំបានជំរាបក្មួយថា ខ្ញុំរៀនបានត្រឹមថ្នាក់ទីប្រាំពីរ
ដល់ឪពុករបស់ខ្ញុំគាត់បានស្លាប់ទៅ ខ្ញុំក៏ឈប់ពីការសិក្សាទៅ។
ក៖ តើលោកពូមានបានរៀន ភាសាផ្សេងក្រៅពីភាសាខ្មែរ ដែរឬទេ?
ខ៖ គឺជំនាន់នោះខ្ញុំអត់មានរៀនអីផ្សេងទេ ពីព្រោះអត់មានលុយកាក់ទៅរៀននឹងគេ
គឺចប់សិក្សាត្រឹមថ្នាក់ទីប្រាំពីរតែម្តង។
ក៖ ចឹង សាលាដែលលោកពូបានរៀន មានឈ្មោះអ្វីដែរ? តើលោកពូមានបានចាំអត់?
ខ៖ សាលារបស់ខ្ញុំបាទ គឺសាលារាលស្សរនឹងឯង។
ក៖ ខ្ញុំសូមការអនុញ្ញាតពីលោកពូបន្តែម ដើម្បីសួរអំពីបទពិសោធន៍ល្អ
នៅក្នុងជីវិតរបស់លោកពូ។ តើបទពិសោធន៍ដ៏ល្អបំផុត ដែលលោកពូបានគិត
ដែលោកពូបានចងចាំរាទុក តើជាបទពិសោធន៍អ្វី
ដែរលោកពូគិតថារាល់នៅក្នុងជីវិតរបស់លោកពូ?
ខ៖ បទពិសោធន៍របស់ខ្ញុំ កាលបែកពីភ្នំពេញឆ្នាំ៧៩ គេបានហៅខ្ញុំឲ្យចូលធ្វើការនៅវិទ្យុជាតិ។
ហើយចងចាំជាទីបំផុត កាលនោះអត់ទាន់មានមនុស្សទេ មានតែមនុស្ស១៨នាក់ទេ
នៅកន្លែងដែលខ្ញុំទៅធ្វើការនោះ។ រួចខ្ញុំ គេមិនឲ្យធ្វើការអ្វីខ្លាំងទេ
គឺគ្រាន់តែនេសាទយកត្រីទៅចិញ្ចឹមពួកគាត់អស់នោះ។ ហើយបន្ទាប់មកទៀត
ដល់គេឃើញខ្ញុំចឹង គេក៏ឲ្យខ្ញុំទៅបើកបរ ហើយបើកបររថយន្តឲ្យខ្ញុំដឹកភ្ញៀវទេសចរណ៍
ដូចជាអាឡឺម៉ង់អី សូវែតអី។ កាលនោះគេមកទស្សនានៅក្នុងស្រុកយើងនឹង
កាលជំនាន់នោះខ្ញុំបានជួយរដ្ឋកម្ពុជាប៉ុណ្ណឹង មកដល់សព្វថ្ងៃនេះខ្ញុំចូលនិវត្តន៍ហើយ។
ក៖ ចឹងលោកពូ តើលោកពូបានជំនះរាល់ឧបសគ្គ ដែលលោកពូគិតថា?
តើលោកពូបានជំនះការលំបាកនឹង យ៉ាងដូចម្តេចទៅ?
ខ៖ ខ្ញុំខំតស៊ូណាស់ កាលនោះអត់ទាន់មានប្រាក់ខែទេ មានតែអង្ករ។ ម្ល៉ោះហើយ
ខ្ញុំគិតថាជីវប្រវត្តិរបស់ខ្ញុំលំបាក ពីជំនាន់ប៉ុលពតរួចហើយ ម្ល៉ោះហើយ ទោះមានអីអត់អី
ក៏ខ្ញុំទ្រាំដើម្បីរស់មកដល់ពេលសព្វថ្ងៃនឹង។
ក៖ ចឹងលោកពូ ខ្ញុំសូមអរគុណលោកពូចំពោះការអនុញ្ញាត
ដើម្បីឲ្យខ្ញុំធ្វើការសំភាសន៍លោកពូណា។ ចឹង តើលោកពូមានចំណាប់អារម្មណ៍
ឬក៏គិតយ៉ាងដូចម្តេចដែរ សំរាប់ការសំភាសន៍មួយនឹង របស់សាកលវិទ្យាល័យនៅអាមេរិច?
តើលោកពូមានចំណាប់អារម្មណ៍ យ៉ាងម៉េចដែរ ចំពោះការសំភាសន៍របស់ពួកខ្ញុំចំពោះលោកពូ?
ខ៖ ខ្ញុំចាប់អារម្មណ៍ ដែលក្មួយសំភាសន៍ខ្ញុំនឹង ទាក់ទងនិងសាលាមួយនោះ
ដើម្បីយកពាក្យដែលសំភាសន៍ខ្ញុំ យកទៅស្រុកអាមេរិចចឹងណោះក្មួយ?
ខ្ញុំជាសប្បាយណាស់ដែលសាលនឹង ជួយផ្សព្វផ្សាយអំពីជីវប្រវត្តិរបស់ខ្ញុំ ដែលខ្ញុំក្រីក្រវេទនានឹង
ប្រហែលជាគេអាចនិងឧបត្ថម្ភដល់ពូ ពូពិតជាត្រេកអរណាស់។
ក៖ ចឹង លោកពូពួកខ្ញុំសុំការអនុញ្ញាតដើម្បីថតរូចខ្លះៗ
របស់លោកពូដើម្បីដាក់ទៅក្នុងវេបសាយរបស់សាលា។ តើលោកពូអនុញ្ញាតដើម្បីឲ្យពួកខ្ញុំថតរូប
របស់លោកពូដែរទេ?
ខ៖ បាទ! ខ្ញុំអនុញ្ញាតឲ្យថតបាន ពីព្រោះរឿងនេះមិនមែនគេយកទៅណាទៅណីទេ
គឺខាងសាលាដែលគេឲ្យក្មួយមកចុះផ្ទាល់តែម្តង បាទអរគុណ។
ក៖ ចាស! សូមអរគុណជំរាបលាលោកពូ៕